# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

## ការចុះបញ្ជិកានៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

**យោងតាមព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥** ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងក្នុងមាត្រា២ ថា "ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យការងារនិងអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា"

**យោងតាមអនុក្រឹត្យ លេខ ០៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពី** "ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ"

**យោងតាមសារាចរណែនាំលេខ ០១.សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី** "ការលើកកម្ពស់គុណភាពនិងប្រសិទ្ធិភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ"

**យោងតាមប្រកាសលេខ ០៧២/១១ ក.ប/ប្រ.ក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពី** *"ចុះបញ្ជិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ"*

### គ្រឹះស្ថានណាខ្លះត្រូវចុះបញ្ជិកា

គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ទាំងអស់ដែលស្ថិតក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ឬក៏ក្រសួងផ្សេងៗក៏ដូចជាគ្រឹះស្ថាន TVET ឯកជនដែលបានសហការជាមួយដៃគូរអភិវឌ្ឍន៍ ក្រុមហ៊ុនឯកជន អង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិទាំងអស់ ដែលកំពុងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលរយៈពេលវែងជាប្រចាំ ត្រូវមកចុះបញ្ជិកាជាមួយនឹង MLVT។

| |
|---|
| *ចុះបញ្ជិកាជាតម្រូវការស្របច្បាប់សម្រាប់រាល់គ្រឹះស្ថាន TVET ទាំងអស់ត្រូវមកចុះបញ្ជិកាក្រោម MLVT* |

### អត្ថប្រយោជន៍នៃការចុះបញ្ជិកា

- នឹងទទួលបានការផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាជាផ្លូវការ
- វិញ្ញាបនបត្រនិងសញ្ញាបត្រដែលសិក្ខាកាម សិស្ស និស្សិតទទួលបានពីការបណ្តុះបណ្តាលនឹងត្រូវបានទទួលស្គាល់ដោយ MLVT និងប្រើប្រាស់បានទូទាំងប្រទេស
- គ្រឹះស្ថាន TVET ដែលបានចុះបញ្ជិការួចនឹងមានសិទ្ធិចូលជាសមាជិកនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- គ្រឹះស្ថាន TVET ដែលបានចុះបញ្ជិការួចនឹងមានសិទ្ធិចូលរួមក្នុងសកម្មភាព TVET ផ្សេងៗដែលរៀបចំឡើងនិង/ឬឧបត្ថម្ភដោយក្រសួងដូចជាសិក្ខាសាលាផ្សេងៗ
- នឹងទទួលបានការធានាគុណភាពនៃការបណ្តុះបណ្តាលពីយន្តការនៃការធានាគុណភាពរបស់ក្រសួងដែលនឹងលើកកម្ពស់ឱកាសការងារដល់សិក្ខាកាម សិស្សនិងនិស្សិត
- គ្រឹះស្ថាន TVET ដែលបានចុះបញ្ជិការួចនឹងមានសិទ្ធិដាក់ពាក្យស្នើសុំមូលនិធិជាតិបណ្តុះបណ្តាលជំនាញផ្សេងៗ
- គ្រឹះស្ថាន TVET ដែលបានចុះបញ្ជិការួចនឹងក្លាយជា សមាជិកឬបណ្តាញនៃសមាគមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈកម្ពុជា អាចចូលរួមក្នុងសកម្មភាពផ្សេងៗ
- សិស្សដែលបានបញ្ចប់វគ្គពីគ្រឹះស្ថាន TVET ទាំងឡាយណាដែលទទួលស្គាល់ជាផ្លូវការ នឹងមានឱកាសល្អក្នុងការទទួលបានការងារ ខណៈដែលមានការទទួលស្គាល់សញ្ញាបត្រជាផ្លូវការនិងគុណភាពនៃការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន

### ការិយាល័យសម្រាប់ទំនាក់ទំនង

ការិយាល័យគ្រប់គ្រងគ្រឹះស្ថានសិក្សា នៃនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។



| ប្រធានការិយាល័យ<br>ទូរស័ព្ទ៖ ០១១ ៩៥៥ ៨៨៦ | អនុប្រធានការិយាល័យ<br>ទូរស័ព្ទ៖ ០១២ ៧៣៨ ១៦៥ |
|---|---|
| **Email: tvetregistered@gmail.com** | |



***សំណុំឯកសារនៃការចុះបញ្ជិកានេះនឹងអាចរកបានតាមមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី/ខេត្តឬក៏នៅនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬក៏អាចទាញយកពីគេហទំព័រ*

**http://www.ntb.gov.kh/registration.html**